៣៤/៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣០
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ"
ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នាថ្ងៃទីដប់បី ខែកុម្ភៈ ឆ្នាំពីរពាន់ដប់ប្រាំបី វេលាម៉ោងប្រាំបី និង សាមសិបនាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូង ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តបាត់ដំបង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៣០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទៈ

១/ឈ្មោះ [redacted] ផាត ភេទប្រុស អាយុ ៥៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើចំការ ទីកន្លែងកំណើតភូមិក្រូចឆ្មា ឃុំក្រូចឆ្មា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃ ភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "ស្លាប់" ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ទោសពីមុន គ្មាន ។ (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣១៩ ត.ព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ) ។

-មានលោក [redacted] រ៉ាវី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ណេម ផាត ។

២/ឈ្មោះ [redacted] នឿន ភេទប្រុស អាយុ ៤៥ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិប្រើសលើ ឃុំតាសែន ស្រុកទ្រាំងខេត្តតាកែវ មានទីលំនៅសព្វថ្ងៃ [redacted] ស្រុកកំរៀង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០៣ នាក់ ទោសពីមុន គ្មាន ។ (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣២០ ត.ព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៧) ។

-មានលោក [redacted] អ៊ាន់ ជាមេធាវីការពារសិទ្ធជនជាប់ចោទ ឈ្មោះ [redacted] នឿន



CamScanner

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៧ ចំណុច ៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៦១៤ ដស.សព ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខៈ ៦៦២ ដ.ដ.រ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ៦១៨៧ ត.ព ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖**

កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៧ វេលាម៉ោង ១២ និង ៣០ នាទីកម្លាំងប្រឆាំងគ្រឿងញៀនសហការជាមួយកម្លាំងការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការនគរបាលខេត្តបាត់ដំបង បានចុះប្រតិបត្តិការបង្ក្រាបករណីជួញដូរគ្រឿងញៀននៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ដោយឃាត់ខ្លួនបានជនជាប់ចោទបានចំនួន ០២ នាក់ មានឈ្មោះ [redacted] នឿន ភេទប្រុស និង ឈ្មោះ [redacted] ថាត ភេទប្រុស ហើយបានដកហូតថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកកICE) ចំនួន ១០ ថង់ធំ ទម្ងន់ ៩៧៦,៧០ ក្រាម និង យ៉ាម៉ាគ្រាប់ចំនួន ៤៨ ថង់ ក្នុងនោះមាន ៩៥៧២ គ្រាប់ ទម្ងន់ ៨៨៩,៦០ ក្រាម ពីជនជាប់ចោទទាំងពីរនាក់ ។ ថ្នាំញៀននេះជនជាប់ចោទឈ្មោះ [redacted] ថាត បានទិញពីឈ្មោះ ណាក់ អ្នករត់ម៉ូតូឌុប ហើយយកមកលក់ឲ្យឈ្មោះ [redacted] នឿន តាមការកុម្ម៉ង់ទិញ ។

**នាពេលសួរចម្លើយ** 

**នាពេលសវនាការ**

-ជនជាប់ចោទ ឈ្មោះ [redacted] នឿន បានឆ្លើយថា៖ កាលពីថ្ងៃកើតហេតុឈ្មោះ [redacted] នាថ ហៅ គីម ភេទស្រី បានពឹងពាក់ឲ្យខ្លួនរកទិញថ្នាំញៀនឲ្យគាត់ ។ ហើយខ្លួនក៏សួរនាំឈ្មោះ [redacted] ថាត ថាមានគ្រឿងញៀនឬ អត់ ហើយពេលនោះឈ្មោះ [redacted] ថាត ថាមានថ្នាំញៀន ។បន្ទាប់មកខ្លួនក៏ទំនាក់ទំនងទៅឈ្មោះ [redacted] ថាត ទៅជួបនៅចំការរបស់ខ្លួន នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៧ នៅម៉ោង១២ និង៣០ នាទី នៅពេលនោះឈ្មោះ [redacted] ថាត បានយកថ្នាំញៀនម៉ាកទឹកកកមកចំនួន ៩ ខាំជាង និង ថ្នាំញៀនប្រភេទគ្រាប់ជិត ១០០០០ គ្រាប់ ទៅជាមួយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង ។ ពីមុនមកខ្ញុំបាទមិនដែលលក់គ្រឿងញៀនទេ ។ ខ្លួនពិតជាបានទំនាក់ទំនងទៅឈ្មោះ [redacted] ថាត ឲ្យយកគ្រឿងញៀនលក់ឲ្យចែគីម ប្រាកដមែន ហើយ ចែគីមបានឲ្យខ្លួនទិញគ្រឿងញៀនឲ្យគាត់ ដោយឲ្យផលចំណេញ ៣,៥ បាត ក្នុង ០១ គ្រាប់ ។ ឈ្មោះ [redacted] ថាត បានប្រាប់មកខ្លួនថា បើមានគេទាក់ទងទិញថ្នាំញៀនពីគាត់ ឲ្យទាក់ទងទៅគាត់ទៅ ។ ពេលដែលសមត្ថកិច្ចឃាត់ខ្លួនដកហូតអត្តសញ្ញាណប័ណ្ណ ទូរស័ព្ទចំនួន ០១ គ្រឿង អិនចុចពិល កាត់គ្រីម៉ូតូចំនួន ០២ លុយចំនួន ៧០០០០ រៀល ។ ចំពោះថ្នាំញៀនជារបស់ឈ្មោះ [redacted] ថាត ។ ឈ្មោះ [redacted] ថាត រកស៊ីគ្រឿងញៀនយូរហើយ ។ ខ្លួនទើបតែទំនាក់ទំនងទិញគ្រឿងញៀន បានតែមួយលើកនេះ ។

ជនជាប់ចោទឈ្មោះ [redacted] ថាត បានឆ្លើយថាៈ បានជាសមត្ថកិច្ចឃាត់ខ្លួនរូបខ្លួន ដោយសារកាលពីថ្ងៃកើតហេតុមិនចាំថ្ងៃ ខែមីនា ឆ្នាំ២០១៧ ខ្លួនពិតជាបានយកគ្រឿង

ញៀនខាងលើទៅលក់ឲ្យឈ្មោះ [redacted] នឿន ពិតមែន ។ គ្រឿងញៀនដែលខ្លួនយកទៅលក់ឲ្យឈ្មោះ [redacted] នឿន គឺខ្លួនទិញពីអ្នករត់ម៉ូតូឌុប ។ខ្លួនមិនដឹងថាថ្នាំញៀននៅថ្ងៃកើតហេតុនោះ មានតម្លៃ ប៉ុន្មានទេ ។ ខ្លួនស៊ីឈ្នួលយកគ្រឿងញៀនឲ្យគេទេ ។ គ្រឿងញៀននោះជារបស់អ្នករត់ម៉ូតូឌុប ។ ឈ្មោះ [redacted] នឿន បានទំនាក់ទំនងទិញថ្នាំញៀនពីខ្លួន ។ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនចំនួនខាងលើ ។ ចម្លើយនេះជាចម្លើយពិត ។ ខ្លួនដឹងថាការជួញដូរថ្នាំញៀនជាអំពើខុសច្បាប់ ។ ខ្លួនដឹងខ្លួនខុសហើយ ។ ខ្លួនទើបតែប្រព្រឹត្តជាលើកទី មួយ នេះទេ ។ ខ្លួនស្គាល់ឈ្មោះ ណាក់ ជាអ្នករត់ម៉ូតូឌុប តែមិនស្គាល់ទីលំនៅទេ ។ ខ្លួនបានពឹងឈ្មោះ ណាក់ ឌុបខ្លួនទៅចំការ ហើយក៏សួរឈ្មោះ ណាក់ ថា មានថ្នាំញៀនដែរឬអត់ ឈ្មោះ ណាក់ថា មាន ខ្លួនក៏សុំទិញ ។ ហើយក៏ឈ្មោះ ណាក់ បានយកថ្នាំញៀនមកឲ្យខ្លួន ហើយក៏ជិះម៉ូតូចេញទៅ ។ ខ្លួនពិតជាបានយកថ្នាំញៀនម៉ាទឹកកកចំនួន០១ គីឡូ និង ថ្នាំគ្រាប់ចំនួន ១០០០០ គ្រាប់ មកលក់ឲ្យឈ្មោះ សោម នឿន ពិតមែន ។
គ្រឿងញៀននោះ ឈ្មោះ ណាក់ បានប្រើខ្លួនឲ្យយកថ្នាំញៀនឲ្យឈ្មោះ [redacted] នឿន ដោយឈ្មោះ ណាក់ សន្យាថា ឲ្យខ្លួនចំនួន ១០០០ ដុល្លារអាមេរិក ។ ខ្លួនមានការរាងចាលហើយឈប់ប្រព្រឹត្តដូចនេះទៀតហើយ ។ខ្លួនមានជំងឺទឹកនោមផ្អែម និង អាឡេកស៊ី ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនៅពេលសវនាការ និង ក្រោយពីបានពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចរាល់ ឃើញថា ពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] នឿន និង ឈ្មោះ [redacted] ផាត ពីបទ:ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៧ ប្រាកដមែនភស្តុតាងដាក់បន្ទុក ដូចនេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ១៦១៤ ដស.សព ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ទុកនៅដដែល និង ប្តឹងសុំទៅលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះនិង ចៅក្រមប្រឹក្សា សម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

មេធាវី [redacted] រ៉ារី ធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផាត ថា៖ កូនក្តីខ្លួនបានសារភាពនូវទោសកំហុស មានការស្តាយក្រោយចំពោះកំហុស និង សហការជាមួយសមត្ថកិច្ចរកមុខជនឈ្មោះ ណាក់ ដែលជាមេខ្លោងគ្រឿងញៀន ។ និង ដោយយោងទៅលើលទ្ធផលកោសលវិច្ច័យ ឃើញថាមិនដល់ ៥០ ភាគរយទេ ដូចលោកចៅក្រមបានពិនិត្យរួចហើយ ។ ដូចនេះខ្លួនសុំដល់ចៅក្រមសម្រាលទោស កូនក្តីខ្លួនតាមមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មេធាវី [redacted] អ៊ាន់ បានធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នឿន ថា៖កូនក្តីខ្លួនបានឆ្លើយសារភាពថាថ្នាំញៀននោះ គឺមិនមែនជារបស់ខ្លួនទេ ដូចនេះខ្លួនសុំដល់លោកប្រធានក្រុមប្រឹក្សានិងលោកចៅក្រមប្រឹក្សាជួយសម្រាលទោសដល់កូនក្តីខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] នឿននិយាយសម្តីចុងក្រោយថា សុំឲ្យតុលាការសម្រាលទោស ។



CamScanner

ជនជាប់ចោទឈ្មោះ [redacted] ថាត និយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការជួយសម្រាលទោស ព្រោះខ្លួនដឹងកំហុសរួចហើយ និង សន្យាកែខ្លួនធ្វើជាពលរដ្ឋល្អចូលទៅរស់នៅក្នុងសង្គមជាតិវិញ ។

-ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ។

-ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ថាត ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់មេធា[redacted] អ៊ាន់ ធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិឲ្យជនជាប់ចោទ [redacted] នឿន ។

-ក្រោយពីបានស្តាប់មេធាវី [redacted] រ៉ាវី ធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថាត ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ថាត ។

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តបាត់ដំបង**

**យល់ឃើញថា**

១/កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ នៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ពិតជាមានបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] នឿន និង ឈ្មោះ [redacted] ថាត ប្រាកដមែន ។

២/អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន ដែលបានទំនាក់ទំនងទៅជនជាប់ចោទឈ្មោះ [redacted] ថាត ដើម្បីទិញគ្រឿងញៀនពីឈ្មោះ [redacted] ថាត យកមកលក់ឲ្យឈ្មោះ គីម ហើយក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន ឃើញថា ជនជាប់ចោទទាំងពីរនាក់នេះពិតជាបាន ធ្វើសកម្មភាព ទំនាក់ទំនងគ្នាទិញគ្រឿងញៀនខុសច្បាប់មកដើម្បីលក់ចេញពីម្នាក់ទៅម្នាក់ទៀត ហើយមានភាពស៊ីសង្វាក់គ្នាទៅនឹងវត្ថុតាងជាគ្រឿងញៀនដូចមាននៅក្នុងសំណុំរឿងព្រមទាំងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ នាំឲ្យតុលាការកំណត់ពីអំពើជាសត្យានុម័ត របស់ជនជាប់ចោទទាំងពីរនាក់ គឺជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៧ ចំណុច ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣/ជនជាប់ចោទឈ្មោះ [redacted] នឿន និង ឈ្មោះ [redacted] ថាត ពិតជាមានចេតនាទុច្ចរិត ក្នុងការចង់បានផលចំណេញពីការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៤/ជនជាប់ចោទឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] ថាត ជាបុគ្គលដែលមានស្មារតីដឹងអំពីផលវិបាកនៃបទល្មើសដែលខ្លួនបានប្រព្រឹត្ត ហើយច្បាប់គ្មានកំណត់ថាបានដល់នីតិភាពក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។

៥/អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] ថាត បាន បញ្ជាក់យ៉ាងច្បាស់អំពី ការប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម

ប្រាកដមែន ។

៦/តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនបានបញ្ជាក់ពីលទ្ធផលលើសំណាកទី១ជា ប្រភេទម្សៅក្រាមពណ៌ស,ទម្ងន់៤,៣៨៧០ ក្រាម ថា វិជ្ជមាន,វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Methamphetamine) គិតជាភាគរយនៃទម្ងន់ ៧២,៣២ % ។ ដូចនេះសំណាក ទី១ ជាសារធាតុញៀនទម្ងន់ ៩៤១,៣ ក្រាម មានកម្រិតសារធាតុញៀនឈ្មោះ មេតំហ្វេតា មីន (Methamphetamine)ទម្ងន់សរុប ៣០៧,៤៦ ក្រាម និង សំណាកទី២ ជាប្រភេទ ថ្នាំគ្រាប់រាងមូលប៉ោងសងខាង ពណ៌ក្រហមឆ្អឹងចំនួន ១០ គ្រាប់ មានសញ្ញាសម្គាល់Logo ជាអក្សរឡាតាំង WY តែម្ខាង ទម្ងន់សរុប ០,៩៣៥៨ ក្រាម បានបញ្ជាក់ជាលទ្ធផល ថា វិជ្ជមាន,វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Methamphetamine) គិតជាភាគរយ នៃទម្ងន់ ៩.១០ % ។ ដូចនេះសំណាកទី២ ដែលជាថ្នាំញៀនប្រភេទគ្រាប់ ចំនួន ៩៥៧១ គ្រាប់ ក្នុង០១ គ្រាប់ទម្ងន់ជាមធ្យម ០,០៩៣៥ ក្រាម មានកម្រិតសារធាតុញៀនឈ្មោះ មេតំហ្វេ តាមីន (Methamphetamine) ទម្ងន់សរុប ៨១,៤៣ ក្រាម ។តាមការបូកបញ្ចូលគ្នាសារធាតុ ញៀនឈ្មោះ មេតំហ្វេតាមីន (Methamphetamine)ទាំងពីរឃើញថាមាន ទម្ងន់សរុបចំនួន ៣៨៨,៨៩ ក្រាម គឺវាស្ថិតក្នុងស្ថានទម្ងន់នៃបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុ ញៀន ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៧ ចំណុចទី៤ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧/វត្ថុតាងចាប់យករួមមាន៖

- ទូរស័ព្ទម៉ាកអិនចុចពិលចំនួន០១ គ្រឿង គប្បីតុលាការរឹបអូសជាសម្បត្តិរដ្ឋ ។
- សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានទម្ងន់សរុប ៣៨៨.៨៩ ក្រាម គប្បីតុលាការរឹបអូសបំផ្លាញចោល ។

៨-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]នឿន និង ឈ្មោះ [redacted] ថាត ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## **សាលាដំបូងខេត្តបាត់ដំបង**

## **ទនិច្ឆ័យសេចក្ត**

១/ផ្តន្ទាទោសលើជនជាប់ចោទ:

១.១/ ឈ្មោះ[redacted] នឿន ភេទប្រុស ៤៥ ឆ្នាំ

១.២/ ឈ្មោះ[redacted] ថាត ភេទប្រុស ៥៣ ឆ្នាំ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗរយៈពេល ២០ (ម្ភៃ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន និង ពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល បង់ចូលថវិការរដ្ឋ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែល មានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

២/វត្ថុតាងចាប់យករួមមាន៖



CamScanner

- ទូរស័ព្ទម៉ាកអ៊ិនចុចពិល ចំនួន ០១ គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ ។

- សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានទម្ងន់សរុប ៣៨៨.៨៩ ក្រាម រឹបអូសបំផ្លាញចោល ។

៣/សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] ផាត និង ប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខានិង ត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខានិងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បាត់ដំបង,ថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០១៨

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]